ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០០២/១៤ បក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ២០១៤

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែធ្នូ ឆ្នាំ២០១៣
## និងទិសដៅការងារ ខែមករា ឆ្នាំ២០១៤

(ពីថ្ងៃទី០១/១២/២០១៣ ដល់ ថ្ងៃទី៣១/១២/២០១៣)

ខែធ្នូឆ្នាំ២០១៣នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន (២០១៣-២០១៥) និងទិសដៅការងារដែលបានដាក់ចេញកាលពីខែវិច្ឆិកា ឆ្នាំ២០១៣ កន្លងទៅ ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សា សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម លើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ទទួលបានលទ្ធផលដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តន៍ច្បាប់ ជាអាទិ៍ មន្ទីរប្រឆាំងគ្រឿងញៀន និងរបាយការណ៍ពីគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានីភ្នំពេញ, ខេត្តកណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ចាម, ព្រះសីហនុ, សៀមរាប, ស្វាយរៀង, ស្ទឹងត្រែង, បាត់ដំបង, កោះកុង, បន្ទាយមានជ័យ, ពោធិ៍សាត់, ក្រចេះ និង មណ្ឌលគិរី ដែលបានរាយការណ៍ពីលទ្ធផល នៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបនៅក្នុងខែធ្នូ ឆ្នាំ២០១៣ នេះ បានកត់សំគាល់ឃើញមានបទល្មើសចរាចរគ្រឿងញៀនខុសច្បាប់នូវមេតំហ្វេតាមីនក្រាមម្សៅ (ICE) ចំនួនពីរករណី ត្រូវបានមន្ទីរប្រឆាំងគ្រឿងញៀនបង្ក្រាបនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ព្រមទាំងចាប់យកនូវគ្រឿងញៀនប្រភេទខាងលើនេះក្នុងចំនួនគួរកត់សំគាល់ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone , Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website: www.nacd.gov.kh

# II. អំពីការងារដឹកនាំ និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ១. អំពីការងារដឹកនាំ

### ១.១. ការងារដឹកនាំរបស់ស្ថាប័នកំពូលថ្នាក់ជាតិ

ក្នុងខែធ្នូនេះ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខ បានចាត់តាំងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាតំណាងដ៏ខ្ពង់ខ្ពស់ចូលរួមក្នុងទិវា "ពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូ ២០១៣" នៅសាលសន្និសីទចតុមុខ និងបានអនុញ្ញាតជាគោលការណ៍ឱ្យអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ទ្វេភាគី-ត្រីភាគី ថ្នាក់រដ្ឋមន្ត្រី កម្ពុជា ឡាវ វៀតណាម លើកទី១៣ ដើម្បីត្រួតពិនិត្យអំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

### ១.២. ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តណែនាំ និងដឹកនាំបញ្ហាលើការងារជាគោលសំខាន់ៗ ជាអាទិ៍ :

- **អំពីគោលការណ៍ណែនាំ និងការដឹកនាំបញ្ហា** ឯកឧត្តមបានណែនាំឱ្យអគ្គលេខាធិការដ្ឋានរៀបចំសមាសភាពក្រុមការងារអន្តរក្រសួងសមាជិកអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាថ្មី, អនុញ្ញាតឱ្យអគ្គលេខាធិការដ្ឋាន បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាលក្នុងការរៀបចំវគ្គបណ្តុះបណ្តាល បំប៉ន ស្តីពីការព្យាបាល ការថែទាំ និងការផ្តល់ប្រឹក្សាអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍, ណែនាំឱ្យខិតខំជំរុញការប្រែក្លាយ "មណ្ឌលបណ្តុះបណ្តាលជនពិការស៊ីវល្លិ៍" នៅខេត្តបន្ទាយមានជ័យ ទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈទូទៅ សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀនដែលបានព្យាបាលធូរស្រាល, អនុញ្ញាតឱ្យបន្តចុះធ្វើអភិបាលកិច្ចនៅសាលានគរបាលភូមិភាគ១ និងភូមិភាគ៣, ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ និងចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ព្រមទាំងអនុញ្ញាតឱ្យថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមក្នុងសិក្ខាសាលាស្តីពីការចាប់ផ្តើមរៀបចំផែនការជាតិអភិវឌ្ឍន៍កុមារ ឆ្នាំ២០១៥-២០២៥ ។
- **អំពីលិខិតបទដ្ឋានគតិយុត្តិ** ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានណែនាំឱ្យជំរុញការរៀបចំសេចក្តីព្រាង "គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តន៍ច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់"និង"គោលនយោបាយ និង គោលការណ៍ណែនាំស្តីពីការអនុវត្តកម្មវិធី ម្ហុល/ស៊ុរាំង នៅកម្ពុជា" ឱ្យបានឆាប់រហ័ស ។

  **ជាមួយនេះ** ឯកឧត្តម បានណែនាំឱ្យជំរុញការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងពិនិត្យកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ឱ្យស្របទៅនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (ថ្មី) ។

## ២. អំពីលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ផ្តើមចេញពីគោលការណ៍ដឹកនាំ និងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ក៏ដូចជាផែនការអនុវត្តទិសដៅការងារដែលបានដាក់ចេញកាលពី **ខែវិច្ឆិកា ឆ្នាំ២០១៣** កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្ត

អនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### *២.១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័ន ជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយក្នុងកម្មវិធីប្រចាំថ្ងៃ-សប្តាហ៍-ខែ, ការអប់រំតាមសហគមន៍ ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

**ដោយឡែក អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បាន :

- ចូលរួមក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន របស់ក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ ដែលមានសមាសភាពពាក់ព័ន្ធចូលរួមចំនួន **៦០** រូប ។
- រៀបចំផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន នៅ :
  - . សាកលវិទ្យាល័យស្វាយរៀង (០៣/១២/២០១៣) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **៧៦០** នាក់
  - . សាកលវិទ្យាល័យ ជាស៊ីមកំចាយមារ (០៤/១២/២០១៣) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **៦៣០** នាក់
  - . សាកលវិទ្យាល័យបាត់ដំបង (១១/១២/២០១៣) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **៣៨៧** នាក់
  - . សាកលវិទ្យាល័យមានជ័យ ខេត្តបន្ទាយមានជ័យ (១២/១២/២០១៣) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **២៨៩** នាក់
  - . សាកលវិទ្យាល័យអង្គរ ខេត្តសៀមរាប (១៣/១២/២០១៣) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **១៧១** នាក់
  - . សាកលវិទ្យាល័យ ប៊ែលធី អន្តរជាតិ (២១/១២/២០១៤) មានសាស្ត្រាចារ្យ និងនិស្សិត ចូលរួម **១.១៥៦** នាក់
- សហការជាមួយក្រសួងព័ត៌មាន ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបញ្ជ្រាបវិធានការ និងហានិភ័យ ក្នុងការសេពគ្រឿងញៀន ដល់អ្នកសារព័ត៌មាន ពិធីករ ពិធីការិនី និងអ្នកដែលធ្វើការងារពាក់ព័ន្ធជាមួយប្រព័ន្ធផ្សព្វផ្សាយ និងចូលរួមក្នុងមហោស្រពចម្រៀងកុមារថ្នាក់ជាតិ ដែលមានអ្នកចូលរួម **៥០០** នាក់ ។
- សហការជាមួយអគ្គនាយកដ្ឋាន វិទ្យុ និង ទូរទស្សន៍បាយ័ន បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈកម្មវិធីប្រគំតន្ត្រីស្រុកស្រែ នៅស្រុកស្នួល ខេត្តក្រចេះ (១៥/១២/២០១៣) មានមហាជនចូលរួម **១៨.៥០០** នាក់, សហការជាមួយទូរទស្សន៍ហង្សមាស និងក្រុមហ៊ុនខារ៉ាបាវ ក្នុងកម្មវិធីខារ៉ាបាវ នៅក្រុងបាវិត ខេត្តស្វាយរៀង (ថ្ងៃទី២៥/១២/២០១៣) មានអ្នកចូលរួម **១០.០០០** នាក់, ក្រុមហ៊ុនទូរស័ព្ទចល័តស្មាតមូបាល (ពីថ្ងៃទី០២-៣០/១២/២០១៣) នៅតាមបណ្តាក្រុង-ស្រុក និងខេត្តគោលដៅ មានអ្នកចូលរួម **១០៥.៥០០** នាក់ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននៅតាមសហគមន៍ និងបណ្តុះបណ្តាលជនបង្គោលនៅតាមសហគមន៍ ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន *៥* គឺ ខេត្តស្វាយរៀង, ខេត្តប៉ៃលិន, ខេត្តកណ្តាល ខេត្តក្រចេះ និងកំពង់ស្ពឺ នៅក្នុងខែធ្នូឆ្នាំ២០១៣នេះ មានមហាជនចូលរួម ***១៥២.៦៩៧ នាក់*** លើ **៧៧.៩០៥** នាក់ នៃខែវិច្ឆិកា ឆ្នាំ២០១៣ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១** ។

### *២.២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែធ្នូឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តន៍ច្បាប់នៅតែបន្តយកចិត្តទុកដាក់ចូលរួមសហការគ្នាបង្ក្រាបបទល្មើសគ្រឿងញៀនគ្រប់ប្រភេទ សំដៅកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

***ក. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៥៤** ករណី លើ ៤៨ ករណី នៃខែវិច្ឆិកា ឆ្នាំ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១១៧** នាក់ លើ ១០៤ នាក់ នៃខែវិច្ឆិកា ឆ្នាំ២០១៣ ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **១១៧** នាក់ ខាងលើ មានប្រុស ៩៧ នាក់ ស្រី ២០ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ១០៧ នាក់ ( ស្រី ១៩ នាក់), **វៀតណាម** ៩ នាក់ ( ស្រី ១ នាក់), **ឡាវ** ០១ នាក់ ( ប្រុស) ត្រូវសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។
- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ (WY) ១៤,៩៨ ក្រាម, មេតំហ្វេតាមីនក្រាមម្សៅ (ICE) ៦៧៦,០៨ ក្រាម, កញ្ឆា ៣១៤,២០ ក្រាម ។
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក រួមមាន** : ម៉ូតូ ១៦ គ្រឿង, ប្រាក់រៀល ១.២២០.៨០០ រៀល, ប្រាក់អាមេរិក ២៨៣ ដុល្លារ, ប្រាក់បាត ៤២០ បាត, ប្រាក់វៀតណាម ៥០.០០០ ដុង **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី២** ។

ដោយឡែក ជនសង្ស័យចាប់តាមដីកា មាន ៧ ដីកា = មនុស្ស ៧ នាក់ ( ប្រុស) ជនជាតិខ្មែរ ។

***ខ. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង **ខែធ្នូ ឆ្នាំ២០១៣** នេះ មានដូចខាងក្រោម :

- សារធាតុគីមី គិតជា គីឡូក្រាម ចំនួន ៣.០៤៥.១៧០ ត.ក្រ និង ៧០០ ហ្គាឡុង
- វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធសរសៃប្រសាទចំនួន ១១ ត.ក្រ និង ១.៧០១ ក្រាម និង ១៦៨២ មិល្លីក្រាម **ដូចមានក្នុងតារាង ឧបសម្ព័ន្ធទី២**

***គ. ការងារកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន***

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តន៍ច្បាប់នានា និងតុលាការរាជធានី-ខេត្ត នៅក្នុងខែធ្នូនេះ សរុបបានចំនួន ២៨ ករណី = ២៩ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀនទាំង** ០២ សំណាក និង **សំណាកវិជ្ជមាន** ២៧ សំណាក ក្នុងនោះគឺ **:**

-មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២៤ សំណាក = ៨៧ % -មេតំហ្វេតាមីនគ្រាប់ (WY) ០៣ សំណាក = ១១ %

***២.៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

***ក. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***

**ការងារក្នុងប្រទេស**

- បានសហការជាមួយអង្គការ FHI360 និងមណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀបចំកិច្ចពិភាក្សាតុមូលតាមវិទ្យុ ហ្វេស.អឹម ១០២ ដើម្បីបកស្រាយសំណួររបស់ប្រិយមិត្តអ្នកស្តាប់ ដូចខាងក្រោម :
  - ✓ បកស្រាយសំណួរក្រោមប្រធានបទស្តីពី "ការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើគ្រឿងញៀន នៅកម្ពុជា" ថ្ងៃទី០៣/១២/២០១៣។
  - ✓ បកស្រាយសំណួរក្រោមប្រធានបទស្តីពី "កញ្ចប់សេវាគ្រប់ជ្រុងជ្រោយសម្រាប់អ្នកប្រើគ្រឿងញៀន នៅកម្ពុជា" ថ្ងៃទី១៧/១២/២០១ ។
  - ✓ បកស្រាយសំណួរក្រោមប្រធានបទស្តីពី "ការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀន តាមយន្តការភាពជាដៃគូសហគមន៍" ថ្ងៃទី២៤/១២/២០១៣។
- បានសហការជាមួយក្រសួងសុខាភិបាល និងអង្គការ FHI360 រៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការសិក្សាស្រាវជ្រាវពីការអនុវត្តកម្មវិធីបង្ការមេរោគអេដស៍និងគ្រឿងញៀន នៅកម្ពុជា (CIPI) នៅខេត្តសៀមរាប កាលពីថ្ងៃទី០៣/១២/២០១៣ ដែលមានមន្ត្រីពាក់ព័ន្ធនៅថ្នាក់ខេត្តចូលរួមចំនួន **៦៦** នាក់ និងនៅរាជធានីភ្នំពេញ ថ្ងៃទី០៦/១២/២០១៣ ដែលមានមន្ត្រីពាក់ព័ន្ធចូលរួម ចំនួន **៥០** នាក់ (សរុបរួម **១១៦** នាក់) ។
- បានចូលរួមជាភ្ញៀវកិត្តិយស និងជាវាគ្មិនក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី គម្រោងសហគមន៍ស្វែងរកការគាំទ្រសម្រាប់កាត់បន្ថយគ្រោះថ្នាក់ពីមេរោគអេដស៍/ជំងឺអេដស៍ ការប្រើបំពានគ្រឿងញៀន និងការជួញដូរមនុស្ស និងការការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ថ្ងៃទី០៣-០៥/១២/២០១៣ មានអ្នកចូលរួម **៦៧** នាក់ និងថ្ងៃទី១១-១៣/ ១២/២០១៣ មានអ្នកចូលរួម **៥០** នាក់ (សរុប **១១៧** នាក់) ។
- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធស្តីពី ការឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍តាមរយៈកម្មវិធីដៃគូសហគមន៍ (ថ្ងៃទី១៨-២០/១២/២០១៣ នៅខេត្តកោះកុង មានអ្នកចូលរួម **៦៦** នាក់) នៅខេត្តស្ទឹងត្រែង ថ្ងៃទី២៣-២៥/១២/២០១៣ មានអ្នកចូលរួម **៧៧** នាក់) ។
- បានចូលរួមក្នុងកិច្ចប្រជុំអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សាលើពង្រាងស្តីពី "គោលនយោបាយគ្រឿងស្រវឹង" តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព កាលពីថ្ងៃទី០៦/១២/២០១៣ ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន (សមាសភាពចូលរួម **១៤** រូប) ។
- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ទៅចូលរួមស្តាប់ការផ្សព្វផ្សាយលើគម្រោងកែប្រែ និងវាយតម្លៃ HIV ដែលជាគម្រោងថ្មីរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាមេរិក (USAID) កាលពីថ្ងៃទី១១/១២/២០១៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។

***៨. ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

**ការងារក្នុងប្រទេស**

- បានចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលដល់មន្ត្រីក្រសួងសុខាភិបាល និងមន្ត្រីសុខាភិបាលពន្ធនាគារ ស្តីពីសុខភាពផ្លូវចិត្ត និងគ្រឿងញៀន ដូចតទៅ :
  - សម្រាប់គ្រូពេទ្យព្យាបាល ខេត្តសៀមរាប ថ្ងៃទី០២-០៦/១២/២០១៣ ចំនួន **៣២** នាក់

- សម្រាប់គ្រូពេទ្យព្យាបាល ខេត្តបាត់ដំបង ថ្ងៃទី១៦-២០/១២/២០១៣ ចំនួន **៣៣** នាក់
- សម្រាប់គិលានុបដ្ឋាក-យិកា ខេត្តព្រះសីហនុ ថ្ងៃទី០២-០៦/១២/២០១៣ ចំនួន **៣៣** នាក់
- សម្រាប់គិលានុបដ្ឋាក-យិកា ខេត្តកំពង់ចាម ថ្ងៃទី១៦-២០/១២/២០១៣ ចំនួន **៣២** នាក់

(**សរុបរួម ១៣០ នាក់**)

### ***២.៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់***

**ការងារនេះ អគ្គលេខាធិការដ្ឋាន** បាន :

- សហការជាមួយការិយាល័យគ្រឿងញៀននិងឧក្រិដ្ឋកម្ម នៃអង្គការសហប្រជាជាតិ (UNODC) រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងទៅនឹងការរត់ពន្ធខុសច្បាប់ កាលពីថ្ងៃទី០២-០៦/១២/២០១៣ នៅក្រុងបាវិត ខេត្តស្វាយរៀង ដែលមានសិក្ខាកាមមកពីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន (BLO) និងមន្ត្រីអនុវត្តន៍ច្បាប់ ដែលប្រចាំការនៅច្រកទ្វារជ្រៃធំ ក្អមសំណ និង បាវិត សរុប **១៧** រូប ។
- ទំនាក់ទំនងជាមួយក្រសួងយុត្តិធម៌ ដើម្បីស្នើសុំឯកសារពាក់ព័ន្ធការកាត់ទោសជនជាប់ចោទ ចាន់បូទ្ធីឌី ពីបទជួញដូរគ្រឿងញៀន ។

**ដោយឡែក ខេត្តកំពង់ចាម** បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផ្សព្វផ្សាយលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនរបស់ខេត្តកំពង់ចាម ដល់មន្ត្រីនគរបាលអង្គភាពពាក់ព័ន្ធ និងមន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាល សរុបចំនួន **៦៣** នាក់ ។

### ***២.៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ***

ខែធ្នូឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជិតខាង ប្រទេសក្នុង អនុតំបន់ តំបន់ និង អន្តរជាតិ មានដូចខាងក្រោម :

**ការងារក្នុងប្រទេស**

- បានចាត់បញ្ជូនមន្ត្រីជំនាញទទួលបន្ទុកការងារតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម (CLV-DTA) ចូលរួមប្រជុំជាមួយភាគីវៀតណាម ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការមេនៃ CLV-DTA កាលពីថ្ងៃទី០៣/១២/២០១៣ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ។
- បានចាត់មន្ត្រីជាន់ខ្ពស់ ០១ រូប ទៅចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីផ្តល់យោបល់លើខ្លឹមសារសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំគណៈកម្មការចម្រុះ កម្ពុជា-វៀតណាម លើកទី១៣ កាលពីថ្ងៃទី០៥/១២/២០១៣ នៅទីស្តីការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។
- បានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ ត្រីភាគី-ទ្វេភាគី ថ្នាក់រដ្ឋមន្ត្រី កម្ពុជា-ឡាវ-វៀតណាម លើកទី១៣ កាលពីថ្ងៃទី១០-១៣/១២/២០១៣ នៅខេត្តសៀមរាប ដែលមានសមាសភាពចូលរួមសរុប **៦៣** រូប (វៀតណាម ១៤ រូប ឡាវ ១៩ រូប និង កម្ពុជា **៣០** រូប) ។
- បានស្នើសុំការឯកភាព និងចុះហត្ថលេខា ពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន លើគម្រោង H15 ដែលបានកែសម្រួល ។

**ដោយឡែក ខេត្តក្រចេះ** បានរៀបចំកិច្ចប្រជុំជាមួយ ការិយាល័យប្រឆាំងគ្រឿងញៀននៃបញ្ជាការដ្ឋានកងទ័ពការពារព្រំដែន ខេត្តប៊ិញហ្វឿក ប្រទេសវៀតណាម (ធ្វើនៅថ្ងៃទី០៤/១២/២០១៣ នៅស្នងការដ្ឋាននគរបាល ខេត្តក្រចេះ) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន រវាងខេត្តក្រចេះ (កម្ពុជា) និង ខេត្តប៊ិញហ្វឿក (វៀតណាម) ។ ខាងភាគីកម្ពុជាមានមន្ត្រីអនុវត្តន៍ច្បាប់ពាក់ព័ន្ធចូលរួមចំនួន **១០** រូប ។

**ការងារក្រៅប្រទេស**

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំនាយដ្ឋានជំនាញ ០២ រូប បានទៅចូលរួមសន្និសីទតំបន់ស្តីពី ការត្រួតពិនិត្យសារធាតុគីមីផ្សំនៅអាស៊ី ពីថ្ងៃទី០២-០៤/១២/២០១៣ នៅប្រទេសថៃ ។

***ការងារផ្សេងៗ :***

ដើម្បីបំពេញឱ្យការងារត្រួតពិនិត្យគ្រឿងញៀនពហុវិស័យ អគ្គលេខាធិការដ្ឋាន បានអនុវត្តការងារមួយចំនួនបន្ថែមទៀត ជាអាទិ៍ :

- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយផែនការជាតិ ៣ ឆ្នាំ (២០១៣-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី០៤/១២/២០១៣ ដែលមានសមាសភាពអញ្ជើញមកពីមន្ទីរពាក់ព័ន្ធនៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចូលរួមសរុប **៣៤៨** នាក់ ។
- បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស (នៅខេត្តបាត់ដំបង ថ្ងៃទី០៤/១២/២០១៣) និងកិច្ចប្រជុំកម្រិតខ្ពស់ (នៅរាជធានីភ្នំពេញ ថ្ងៃទី០៩/១២/២០១៣) លើសេចក្តីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ឆ្នាំ ២០១៤-២០១៨ តាមការអញ្ជើញរបស់ក្រសួងផែនការ ។
- បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងកែលម្អលើគេហទំព័រគំរូថ្មី របស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កាលពីថ្ងៃទី១៩/១២/២០១៣ និងបានដាក់ឱ្យដំណើរការចាប់តាំងពីខែមករាឆ្នាំ២០១៤នេះ រហូតទៅ ។
- បានរៀបចំសមាសភាពក្រុមការងារអន្តរក្រសួងសមាជិក អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាថ្មី សម្រាប់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ។
- បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២៤/១២/២០១៣ នៅសណ្ឋាគារ អាំងទែ-កុងទីណង់តាល់ ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែមករា ឆ្នាំ២០១៤

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. សហការជាមួយក្រសួងព័ត៌មាន រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការបញ្ជ្រាបវិធានការ និងហានិភ័យ ក្នុងការសេពគ្រឿងញៀន ដល់អ្នកសារព័ត៌មាន ពិធីករ ពិធីការិនី និងអ្នកដែលធ្វើការងារពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយ ។

១.២. ផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែតនៃស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី ស្តីពីយុទ្ធសាស្រ្តជាតិក្នុងការ

ប្រយុទ្ធប្រឆាំងគ្រឿងញៀន (ថ្ងៃទី២៩/០១/២០១៤) ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត វិស័យឯកជន ដើម្បីបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយពាណិជ្ជកម្ម នៅតាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៤. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយមន្ទីរប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងគ្រឿងញៀន រាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ក្នុងការស្រាវជ្រាវរកខ្សែរយៈទាក់ទងដែលនៅសេសសល់ពាក់ព័ន្ធនឹងករណីធំៗដែលបង្ក្រាបបានកន្លងមក ។

២.២. ត្រៀមកិច្ចសហការផ្តល់ព័ត៌មានពាក់ព័ន្ធបទល្មើសគ្រឿងញៀនឱ្យគ្នាទៅវិញទៅមក ជាមួយប្រទេសជិតខាង ។

២.៣. ជំរុញកិច្ចប្រជុំឱ្យបានទៀងទាត់ រវាងបណ្តាខេត្តនិងខេត្តជាប់ព្រំដែន កម្ពុជា-ថៃ កម្ពុជា-ឡាវ កម្ពុជា-វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

២.៤. បន្តសហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បីរៀបចំសេចក្តីព្រាងប្រកាសស្តីពីការដាក់ស្លាកសញ្ញាសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

២.៥. បន្តសហការជាមួយអង្គការ UNODC ដើម្បីដំណើរការវិភាគឱ្យបានច្បាស់លាស់ពីរុក្ខជាតិវល្លិ៍រមៀត ដែលសង្ស័យថាមានផ្ទុកសារធាតុគីមីផ្សំសម្រាប់កែច្នៃផលិតជាគ្រឿងញៀនខុសច្បាប់ ។

២.៦. បន្តកិច្ចសហការ សម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ដើម្បីស្នើសុំឯកសារពាក់ព័ន្ធការកាត់ទោសជនជាប់ចោទ **ចាន់ ឬទ្ធីឌី** ពីបទជួញដូរគ្រឿងញៀន ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ត្រៀមទទួលគណៈប្រតិភូនៃក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ ដែលត្រូវមករៀបចំសិក្ខាសាលាបូកសរុប និងវាយតម្លៃ ស្តីពីការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នាថ្ងៃទី១៣-១៦/០១/២០១៤ ។

៣.២. រៀបចំគម្រោងសម្រាប់ការបណ្តុះបណ្តាលពាក់ព័ន្ធផ្នែកព្យាបាល និង ផ្នែកស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគម្រោងតម្រូវការសម្ភារៈ ឱសថ ដែលត្រូវផ្តល់ដោយភាគីវៀតណាម ។

៣.៣. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និង ស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៤. បន្តពិនិត្យលើសេចក្តីព្រាង "គោលនយោបាយ និងគោលការណ៍ណែនាំស្តីពី ការអនុវត្តកម្មវិធី ម្តុល/ស៊ីរ៉ាំង នៅកម្ពុជា និង គោលការណ៍ណែនាំបន្ថែមសម្រាប់គាំទ្រមន្ត្រីអនុវត្តច្បាប់ចំពោះកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៥. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀន ដែលកំពុងសម្រាកព្យាបាល

នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៦. បន្តពង្រឹងសមត្ថភាពការងារព្យាបាលដោយផ្អែកលើសហគមន៍ តាមប្រព័ន្ធសុខាភិបាលដែលមានស្រាប់ ( មន្ទីរពេទ្យបង្អែក-មណ្ឌលសុខភាព) នៅទូទាំងប្រទេស ដោយយកបទពិសោធន៍តាមខេត្តបន្ទាយមានជ័យ និងខិតខំសហការសម្របសម្រួលលើការងារបាលអ្នកញៀនគ្រឿងញៀននៅតាមប៉ុស្តិ៍សុខភាពពន្ធនាគារ ។

៣.៧. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. សហការសម្របសម្រួល និងជំរុញដំណើរការការងាររបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀន នៅខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ ។

៤.២. រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នានា នៅតាមខ្សែបន្ទាត់ព្រំដែន ។

៤.៣. រៀបចំទីកន្លែងសម្រាប់ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ដោយម៉ាស៊ីនកុំព្យូទ័រ (CBT) ។

៤.៤. សហការជាមួយអង្គការ FHI360 រៀបចំកិច្ចប្រជុំតុមូល ដើម្បីពិភាក្សាបន្តលើកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៤.៥. បន្តការចូលរួមធ្វើបទឧទ្ទេសនាមអំពីសភាពការណ៍គ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដល់មន្ត្រីនគរបាលរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ។

៤.៦. ចុះត្រួតពិនិត្យ និងជំរុញការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន នៅតាមបណ្តាខេត្តដែលមានការិយាល័យទំនាក់ទំនងព្រំដែន (BLO) ។

៤.៧. រៀបចំកែសម្រួលឯកសារបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពការការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើប៉ំពានគ្រឿងញៀន ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ចាត់បញ្ជូនមន្ត្រីទៅចូលរួមកិច្ចប្រជុំក្រុមសម្របសម្រួលអន្តរជាតិ Operation Cobra 2 នៅទីក្រុងបាងកក ប្រទេសថៃ ពីថ្ងៃទី០៦-២៦/០១/២០១៤ ។

៥.២. ត្រៀមធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៨ នាថ្ងៃទី០៤-០៧/០២/២០១៤ ។

៥.៣. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញទៅចូលរួមកិច្ចប្រជុំស្តីពី ការកែសម្រួលគម្រោង H15 ស្តីពីភាពជាដៃគូក្នុងការពង្រឹងយន្តការអនុតំបន់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន នៃបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ (MOU1993) ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២០-២១/០១/២០១៤ នៅប្រទេសចិន ។

៥.៤. ត្រៀមរៀបចំដំណើរទស្សកិច្ចរបស់ថ្នាក់ដឹកនាំ អ.ជ.ប.គ.ញ ទៅកាន់ប្រទេសវៀតណាម និង ប្រទេសឡាវ ។

៥.៥. បន្តទំនាក់ទំនងជាមួយស្ថានទូតចិន និងក្រសួងសន្តិសុខសាធារណៈចិន ពាក់ព័ន្ធនឹងដំណើរទស្សនកិច្ចរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅសាធារណរដ្ឋប្រជាមានិតចិន ។

ក្រៅពីទិសដៅការងារខាងលើ  អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត  ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ  ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ( ថ្ងៃទី១០/០១/២០១៤) ។
- បន្តអនុវត្តខ្លឹមសារប្រសាសន៍ណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដែលនៅសេសសល់ ។
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៣ និងទិសដៅការងារឆ្នាំ២០១៤ ។

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក មាស-វីរិទ្ធ

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនជាភ៌ អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

**"ដើម្បីជូនជ្រាប"**

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

**"ដើម្បីតម្កល់ទុក"**

-ឯកសារ